ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

តុលាការកំពូល

សាលាព្រហ្មទណ្ឌ

សំណុំរឿងព្រហ្មទណ្ឌ

លេខ : ១៦

ចុះថ្ងៃទី២៤ខែកុម្ភៈឆ្នាំ១៩៩៨

សាលដីកា

លេខ : ៤៩

ចុះថ្ងៃទី៣០ខែកញ្ញាឆ្នាំ១៩៩៨

# ពាក្យនាមប្រជារាស្ត្រខ្មែរ

## តុលាការកំពូល

ក្នុងបើកសវនាការជំនុំជំរះជាសាធារណៈ នៅថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ-១៩៩៨ ដោយមានសមាសភាពដូចតទៅ :

១- ឯកឧត្តម ឌិត មុន្ធី ប្រធាន

២- លោក ឈឹម ស៊ីផល ចៅក្រម

៣- លោក ប្រាក់ គីមសាន ចៅក្រមរបាយការណ៍

៤- លោក សោម សិរីវិឌ្ឍ ចៅក្រម

៥- លោក យស់ សួរខឿន ចៅក្រម

ក្រឡាបញ្ជី

លោក ប៉ុល វណ្ណា

តំណាងមហាអយ្យការ

លោក ដួន ស៊ុនទៀង ជាព្រះរាជអាជ្ញា

ដើម្បីជំនុំជំរះលើបណ្តឹងសាទុក្ខ ពីសាលដីកាព្រហ្មទណ្ឌលេខ ២៤៣ ចុះថ្ងៃទី១៩ ខែធ្នូ-ឆ្នាំ១៩៩៧ របស់សាលាឧទ្ធរណ៍ និង សំណុំរឿងព្រហ្មទណ្ឌលេខ ១៦ ចុះថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ១៩៩៨ របស់ តុលាការកំពូល ។

ពីបទ : បង្ករបួសស្នាមដោយអចេតនា " គ្រោះថ្នាក់ចរាចរ " ប្រព្រឹត្តនៅក្រុងភ្នំពេញ កាលពីថ្ងៃទី២១-២-១៩៩៦ ។ បទល្មើសដែលមានចែង និង ផ្តន្ទាទោសតាមបញ្ញត្តិមាត្រា៥៧ នៃច្បាប់ពីចរាចរផ្លូវគោក ។

- ជនជាប់ចោទឈ្មោះ វ័ន្ត គីមឡេង " ជាម្ចាស់បណ្តឹងសាទុក្ខ " ភេទប្រុស អាយុ ៣៥ឆ្នាំ ជាតិខ្មែរ កើតនៅភូមិក្តីចាស់ ឃុំព្រែកតាឯក ស្រុកមុខកំពូល ខេត្តកណ្តាល របរតាក់ស៊ី-ដោយធ្វើតំបន់ប្រតិបត្តិការបើកខេត្តកណ្តាល មានទីលំនៅបច្ចុប្បន្ន ផ្ទះលេខ២០ភាគីស្ទូន ផ្លូវលេខ ២៩៣ សង្កាត់បឹងកក់២ ខណ្ឌទួលគោក ក្រុងភ្នំពេញ ។ ឪពុកឈ្មោះ វ័ន្ត ឃួន " ស " ម្តាយ-ឈ្មោះ អី យ៉េត " រ " ប្រពន្ធឈ្មោះ កេង សុភ័ន្ត មានកូន០២នាក់ ។ ក្រៅឃុំ ។

- មេធាវី លោក ង៉ា ពិសី

- អ្នកទទួលខុសត្រូវរដ្ឋប្បវេណី អ្នកស្រី សេង សុខុម " ជាម្តាយក្មេកវិន្ត គឹមទេឡុង " អាយុ៥៧ឆ្នាំ ជាតិខ្មែរ មានទីលំនៅសព្វថ្ងៃ ផ្ទះលេខ១២អាគារបេ ផ្លូវលេខ២៨៥ សង្កាត់បឹងកក់២ ខណ្ឌទួលគោក ក្រុងភ្នំពេញ ។

- ដើមបណ្តឹងរដ្ឋប្បវេណី ឈ្មោះ យោគ វណ្ណឌី " ជាចុងបណ្តឹងអាជ្ញា " ភេទប្រុស អាយុ៣៧ឆ្នាំ ជាតិខ្មែរ របររកស៊ីធ្វើយោធា មានទីលំនៅសព្វថ្ងៃ ផ្ទះលេខ២៨អឺផ្លូវ៣ សង្កាត់អូរឫស្សី៣ ខណ្ឌ៧មករា ក្រុងភ្នំពេញ ។ តំណាងអោយជនរងគ្រោះ ០៥នាក់ គឺ :

១- វង្ស សុខាតា ភេទស្រី អាយុ១២ឆ្នាំ

២- សឿង ចិង ភេទស្រី អាយុ១៥ឆ្នាំ

៣- ស្រស់ សុភាព ភេទស្រី អាយុ១៧ឆ្នាំ

៤- ជា ស្រីពៅ ភេទស្រី អាយុ៥៧ឆ្នាំ ជនរងគ្រោះទាំងបួន មានទីលំនៅសព្វថ្ងៃ ផ្ទះលេខ០៥១ សង្កាត់បឹងសាឡាង ខណ្ឌទួលគោក ក្រុងភ្នំពេញ ។

៥- ហម សុធី ភេទស្រីអាយុ១៥ឆ្នាំ មានទីលំនៅសព្វថ្ងៃ ផ្ទះលេខ០៧ ភូមិ-ទួលគោ សង្កាត់ចាក់អង្រែក្រោម ខណ្ឌមានជ័យ ក្រុងភ្នំពេញ ។

- មេធាវី គ្មាន

តាមបណ្តឹងអាជ្ញាលេខ០០៦ ចុះថ្ងៃទី២៧ ខែមករា ឆ្នាំ១៩៩៧ របស់ឈ្មោះវិន្ត គឹមទេឡុង ដែលប្តឹងតវ៉ាពីសាលដីកាព្រហ្មទណ្ឌលេខ៥៤៣ ចុះថ្ងៃទី១៩ ខែធ្នូ ឆ្នាំ១៩៩៦ របស់ សាលាឧទ្ធរណ៍ លើសេចក្តីបំរេបទាំងមូល ។

តាមរបាយការណ៍ចុះថ្ងៃទី ២៥-០២-៩៦ របស់ប៉ុស្តិ៍នគរបាលនិរោធ នៃអធិការដ្ឋាននគរបាល ខណ្ឌមានជ័យ បានបញ្ជាក់ថា : កាលពីថ្ងៃទី២១-០២-៩៦ វេលាម៉ោង២រសៀល លើផ្លូវជាតិលេខ១ ក្នុងភូមិបឹងឈូក សង្កាត់និរោធ ខណ្ឌមានជ័យ មានគ្រោះថ្នាក់ចរាចរមួយកើត រវាងរថយន្តម៉ាក ភាដូវ៉ា ពាក់ស្លាកលេខ ២.៣៩១៦ ភព២ បើកបរដោយឈ្មោះគឹមទេឡុង បើកពីកើតទៅលិច គេចនឹងរ៉ឺម៉ក ឆេវចង្កូតទៅបុកម៉ូតូលេខ១០០ បើកបរដោយឈ្មោះស្រី ពៅ បើកពីលិចទៅកើត និង បុកម៉ូតូដាលី បើកបរដោយឈ្មោះហម សុធី បើកពីលិចទៅកើត បណ្តាលអោយមនុស្ស ០៤នាក់របួសធ្ងន់ និង ៣នាក់របួសស្រាល ខូចខាតម៉ូតូ២គ្រឿង មូលហេតុបណ្តាលមកពីរថយន្ត បើកមិនប្រកាន់ស្តាំ មានល្បឿនលឿន ។

តាមបទចម្លើយដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ យោគ វណ្ណឌី តំណាងអោយជនរងគ្រោះ៥នាក់ ឆ្លើយថា : ខ្លួនស្នើទាមទារជម្ងឺចិត្ត និង សំណងការខូចខាតរបួស និង ពិការដល់ខ្លួន ជាប្រាក់-ចំនួន ២ម៉ឺនដុល្លាអាមេរិក ។

បានឃើញសេចក្តីសន្និដ្ឋានរបស់ តំណាងអយ្យការ អម តុលាការក្រុងភ្នំពេញ ថា :

សំរេចចោទប្រកាន់លើឈ្មោះ វ័ន្ត គីមឡេង ពីបទៈ បង្ករបួសស្នាមដោយអចេតនា -
"គ្រោះថ្នាក់ចរាចរ" ប្រព្រឹត្តនៅក្រុងភ្នំពេញ កាលពីថ្ងៃទី ២១-០២-១៩៩៦ បទល្មើសដែលមានចែងនិងផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៥៧ នៃច្បាប់ចរាចរផ្លូវគោក ។

បានឃើញសាលក្រមលេខ ៣០ "ក" ចុះថ្ងៃទី០៣ ខែកក្កដា ឆ្នាំ១៩៩៦ របស់តុលាការក្រុងភ្នំពេញ ដែលបានសំរេច ៖

១ - ផ្តន្ទាទោសដាក់ពន្ធនាគារឈ្មោះ វ័ន្ត គីមឡេង ចំនួន ១ឆ្នាំ តែទោសនេះត្រូវព្យួរ ក្នុងរយៈពេលសាកល្បង៥ឆ្នាំ គិតចាប់តាំងពីថ្ងៃសាលក្រមនេះ ចូលជាស្ថាពរ ពីបទៈ បង្ករបួសស្នាមដោយអចេតនា "គ្រោះថ្នាក់ចរាចរ" ប្រព្រឹត្តកាលពីថ្ងៃទី ២១-០២-៩៦ នៅក្រុងភ្នំពេញ តាមបញ្ញត្តិមាត្រា ៥៧ នៃច្បាប់ចរាចរផ្លូវគោក និង មាត្រា៧០ នៃក្រមព្រហ្មទណ្ឌអន្តរកាល ។

២ - បង្គាប់អោយឈ្មោះ វ័ន្ត គីមឡេង សងថ្លៃថ្នាំពេទ្យ និង ជម្ងឺចិត្ត អោយឈ្មោះរ៉ុង មួយគីង ចំនួន ៥.០០០ដុល្លា ,អោយទៅឈ្មោះ [illegible] ចំនួន៤.០០០ដុល្លា អោយទៅឈ្មោះជូ សុភាព ចំនួន ២.០០០ដុល្លា , អោយទៅឈ្មោះ ស៊ី ពៅ ចំនួន២០០០ដុល្លា និង អោយទៅឈ្មោះ ចាម សុធី ចំនួន ៤០០០ដុល្លា ដែលមានឈ្មោះ សោភ វណ្ណធី ជាតំណាង សំណុំរឿងពីរនេះ ត្រូវបដិសេធចោល ។

៣ - បង្គាប់អោយឈ្មោះ វ័ន្ត គីមឡេង សងពីរឡានម៉ូតូ រស១០០ និង ម៉ូតូដាស៊ី តាមប្រភេទ និងតំលៃដាក់ដែលអោយទៅម្ចាស់ដើមវិញ ។

៤ - ក្នុងករណីមិនសងទេ ត្រូវដាក់គុកបង្ខំដល់រូបកាយឈ្មោះ វ័ន្ត គីមឡេង និង [illegible] "ផ្ទះលេខ២៣ [illegible] ផ្លូវលេខ ១៨៥ ដែលមានវិញ្ញាបនប័ត្រសំគាល់ម្ចាស់អចលនវត្ថុលេខ ១៩៤៧៥ ចុះថ្ងៃទី២៩-៧-១៩៩៥" លក់ឡាយឡុងដេញថ្លៃ តាមច្បាប់ស្តីពីការដាក់គុកបង្ខំដល់រូបកាយក្នុងរឿងព្រហ្មទណ្ឌ ។

៥ - ប្រគល់ម៉ូតូ រស១០០ ម៉ូតូដាស៊ី និង [illegible] ពាក់ស្លាកលេខ [illegible] អោយទៅឈ្មោះ វ័ន្ត គីមឡេង ។

៦ - សាលក្រមនេះ ប្រកាសជាសាធារណៈ កំបាំងមុខជនជាប់ចោទ សំរេចបើកផ្លូវឧទ្ធរណ៍ ក្នុងរយៈពេល២ខែគិត ចាប់តាំងពីថ្ងៃផុតបណ្តឹងទាស់ ។

បានឃើញបណ្តឹងឧទ្ធរណ៍លេខ៥១ "ក" ចុះថ្ងៃទី១០ ខែកញ្ញា ឆ្នាំ១៩៩៦ របស់ឈ្មោះ វ័ន្ត គីមឡេង និងឈ្មោះ សោភ វណ្ណធី តាមបណ្តឹងលេខ៤៧ "ក" ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ១៩៩៦ ដែលប្តឹងតវ៉ាពីសាលក្រមព្រហ្មទណ្ឌលេខ ៣០ "ក" ចុះថ្ងៃទី០៣ ខែកក្កដា ឆ្នាំ ១៩៩៦ របស់តុលាការក្រុងភ្នំពេញ លើសេចក្តីសំរេចទាំងមូល ។

បានឃើញ សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ អម សាលាឧទ្ធរណ៍ ថា៖ ចំពោះបទល្មើសដែលបើកបរបណ្តាលអោយគ្រោះថ្នាក់ដោយអចេតនាដូច្នេះគួរក្រុមប្រឹក្សា

ពិចារណាអំពីឃើញដូចជាម៉ូតូជាប់តែម្តង ។

បានឃើញសាលដីកាព្រហ្មទណ្ឌលេខ ១៧១ ចុះថ្ងៃទី២៧ ខែសីហា ឆ្នាំ១៩៩៧ របស់សាលាឧទ្ធរណ៍បានសំរេច ៖

១ - ទទួលបណ្តឹងឧទ្ធរណ៍ចុះថ្ងៃទី ១០ - ៩ - ១៩៩៦ របស់ជនជាប់ចោទឈ្មោះ - វ័ន្ត គីមឡឿង និង បណ្តឹងឧទ្ធរណ៍ចុះថ្ងៃទី៣០ - ៨ - ១៩៩៦ របស់ឈ្មោះ ឃោត វណ្ណឌី ជាដើមបណ្តឹងរដ្ឋប្បវេណីទុកជាត្រឹមត្រូវតាមទំរង់ច្បាប់ ។

២ - តម្កល់សាលក្រមព្រហ្មទណ្ឌលេខ៣០ " គ " ចុះថ្ងៃទី៣ - ៧ - ១៩៩៦ របស់តុលាការក្រុងភ្នំពេញ ទុកជាបានការ វៀរលែងចំណុចទី៣ ដែលត្រូវកែប្រែដូចតទៅ ៖

បង្គាប់អោយឈ្មោះ វ័ន្ត គីមឡឿង សងតំលៃម៉ូតូលេខ១០០ ជាទឹកប្រាក់ចំនួន១១០០ដុល្លា ម៉ូតូឆាលីជាទឹកប្រាក់ចំនួន៣០០ដុល្លា អោយទៅម្ចាស់ដើមវិញ ។

៣ - បង្គាប់អោយឈ្មោះ វ័ន្ត គីមឡឿង ផ្តល់ថ្លៃព្យាបាល និងសំណងជំងឺចិត្តចំនួន២០០០ដុល្លា ថែមទៀតអោយទៅឈ្មោះ ជូ ភាព ។

៤ - សាលដីកានេះប្រកាសជាសាធារណៈចំពោះមុខដើមបណ្តឹងរដ្ឋប្បវេណី កំបាំងមុខជនជាប់ចោទ បើកផ្លូវប្តឹងទាស់ និង សាទុក្ខក្នុងកំណត់ច្បាប់ ។

បានឃើញបណ្តឹងទាស់លេខ ៤៤ ចុះថ្ងៃទី២៩ ខែកញ្ញា ឆ្នាំ១៩៩៧ របស់ឈ្មោះ - វ័ន្ត គីមឡឿង ដែលប្តឹងទាស់ ពីសាលដីកាព្រហ្មទណ្ឌលេខ ១៧១ ចុះថ្ងៃទី២៧ ខែសីហា ឆ្នាំ១៩៩៧ របស់សាលាឧទ្ធរណ៍ លើសេចក្តីសំរេចទាំងមូល ។

បានឃើញសាលដីកាព្រហ្មទណ្ឌលេខ២៤៣ ចុះថ្ងៃទី១៩ ខែធ្នូ ឆ្នាំ១៩៩៧ របស់សាលាឧទ្ធរណ៍ដែលបានសំរេច ៖ ១ - ទទួលបណ្តឹងទាស់ចុះថ្ងៃទី២៩ - ៩ - ៩៧ របស់ជនជាប់ចោទឈ្មោះ - វ័ន្ត គីមឡឿង ទុកជាត្រឹមត្រូវតាមទំរង់ច្បាប់ តែបដិសេធចោលដោយខុសនឹងនីតិច្បាប់ ។

២ - តម្កល់សាលដីកាព្រហ្មទណ្ឌលេខ ១៧១ ចុះថ្ងៃទី២៧ ខែសីហា ឆ្នាំ១៩៩៧ របស់សាលាឧទ្ធរណ៍ទុកជាបានការពេញទាំងមូល ។

៣ - សាលដីកានេះប្រកាសជាសាធារណៈកំបាំងមុខជនជាប់ចោទជាលើកទី២ ទុកជាចំពោះមុខ បើកផ្លូវសាទុក្ខក្នុងកំណត់ច្បាប់ ។

បានឃើញបណ្តឹងសាទុក្ខលេខ០៦ ចុះថ្ងៃទី២៧ ខែមករា ឆ្នាំ១៩៩៨ របស់ឈ្មោះ - វ័ន្ត គីមឡឿង ដែលប្តឹងតវ៉ាពីសាលដីកាព្រហ្មទណ្ឌលេខ២៤៣ ចុះថ្ងៃទី១៩ ខែធ្នូ ឆ្នាំ១៩៩៧ របស់សាលាឧទ្ធរណ៍ លើសេចក្តីសំរេចទាំងមូល ។

បានឃើញសារណាចុះថ្ងៃទីគ្មាន ខែមិនា ឆ្នាំ១៩៩៨ របស់ឈ្មោះ វ័ន្ត គីមឡឿង ធ្វើឡើងក្នុងកំណត់ច្បាប់ ។

បានឃើញសារណាឆ្លើយតប ចុះថ្ងៃទី០១ -ខែមេសា ឆ្នាំ១៩៩៨ របស់លោក ឃោត - វណ្ណឌី តំណាងអោយជនរងគ្រោះ ធ្វើឡើងក្នុងកំណត់ច្បាប់ ។

បានស្តាប់ទឡ្ហីករណ៍ របស់ចៅក្រមទឡ្ហីករណ៍

បានស្តាប់សេចក្តីសន្និដ្ឋាន របស់តំណាងមហាអយ្យការ អម តុលាការកំពូល ថា ៖ ទោះបីជនរងគ្រោះក៏បាននាំលោកទៅលើច្បាប់ចរាចរណ៍ផ្លូវគោក និង បទបញ្ជាផ្នែកក្នុង ការធ្វើចរាចរណ៍យ៉ាងពិតប្រាកដ ជាហេតុនាំអោយបាត់ម្ចាស់ការ ក្នុងការគេចអោយផុតពីគ្រោះថ្នាក់បានឡើយ ដូច្នេះជនរងគ្រោះ ក៏ត្រូវរួមចំណែកក្នុងការទទួលខុសត្រូវអំពីព្យសនកម្មដែលបណ្តាលមកពីគ្រោះថ្នាក់ចរាចរណ៍នេះដែរ ។ ក្រោយពីបានពិនិត្យលើសំណុំរឿង និង ឯកសារពាក់ព័ន្ធរួមមក យល់ឃើញថា សាលដីកាព្រហ្មទណ្ឌលេខ ៥៤៣ ចុះថ្ងៃទី១៨ - ១២ - ៩៧ របស់សាលាឧទ្ធរណ៍ដែលបាន សំរេចសេចក្តីមកនេះមានការខុសឆ្គងទាំងទំរង់ និង អង្គច្បាប់ ។ ហេតុនេះសូមក្រុមប្រឹក្សា ជំនុំជំរះ មេត្តាពិនិត្យពិចារណា និង សំរេចតាមច្បាប់តទៅ ។

បានស្តាប់ចម្លើយអះអាងរបស់ជនជាប់ចោទឈ្មោះ វ័ន្ត គឹមឡេង ការការពារក្តីរបស់ តុលាការក្រុងភ្នំពេញ និង សាលដីកាសាលាឧទ្ធរណ៍ដែលបានសំរេចអោយខ្ញុំសងថ្លៃព្យាបាល និង - ជម្ងឺចិត្តអោយទៅជនរងគ្រោះនីទានការធ្ងន់ធ្ងរពេក ហើយវាហួសពីសមត្ថភាពរបស់ខ្ញុំ ដ្បិតខ្ញុំមាន លទ្ធភាពសងទៅជនរងគ្រោះ ដូចតាមសារណារបស់ខ្ញុំ ។

បានស្តាប់ចម្លើយអះអាងរបស់ដើមបណ្តឹងរដ្ឋប្បវេណីលោក ហោ ឌ វណ្ណឌី ដោយផ្អែក លើភស្តុតាងនិងទឡ្ហីករណ៍ របស់នគរបាល មូលដ្ឋានជាក់ស្តែងនៅថ្មីងកន្លែងកើតហេតុហើយថែមការ ស៊ើបអង្កេតរបស់អយ្យការ និង តុលាការចំនួនបីលើកមកហើយ គឺជនល្មើសខុសទាំងស្រុង ចំពោះមុខ ច្បាប់ តែជនល្មើសនៅតែមិនព្រមសារភាព និងទទួលការពិត និងពន្យារពេលបានយូរ ដែលធ្វើអោយ ជនរងគ្រោះ ជំពាក់ការប្រាក់គេកាន់តែច្រើន និង គ្មានប្រាក់ថែរក្សាដំបៅរបួសស្នាមកាន់តែ យ៉ាប់ថែមទៀត ។

បានស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវីការពារជនជាប់ចោទឈ្មោះ វ័ន្ត គឹមឡេង ថា ៖ គឺយល់ព្រមទៅនឹងទឡ្ហីករណ៍របស់ចៅក្រមទឡ្ហីករណ៍ និងទឡ្ហីករណ៍គ្រោះថ្នាក់ចរាចរណ៍ របស់នគរបាលខណ្ឌមានជ័យ ។ គឺការជិះទន្ទឹមគ្នាបីជួរ ហើយម៉ូតូលេខ០០ឌុបគ្នាបួននាក់ ដែលបណ្តាល អោយទប់មិនឈ្នះ និង ម៉ូតូឆាលីក៏បានឌុបគ្នាបីនាក់ដែរ ហើយក្មេងមិនទាន់គ្រប់អាយុជាអ្នកឌុបទៀត ។ តែសាលាក្រមនិងសាលដីកាដែលសំរេចអោយសងសំណងមានភាពអយុត្តិធម៌ គឺសងច្រើនពេកកំហុសនេះគឺ មានទាំងសងខាង ។ ហេតុនេះសុំបដិសេធសាលដីកាសាលាឧទ្ធរណ៍ទាំងមូល សុំអោយពិនិត្យ និង ពិចារណាជួយរកយុត្តិធម៌ ។

បានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ គ្មានយោបល់អ្វីបន្ថែមទៀតទេ ។

- ក្រោយពីបានស្តាប់ទឡ្ហីករណ៍ របស់ចៅក្រមទឡ្ហីករណ៍
- ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ
- ក្រោយពីបានស្តាប់ចម្លើយរបស់ជនជាប់ចោទ របស់ដើមបណ្តឹងរដ្ឋប្បវេណី និង សេចក្តីសន្និដ្ឋានការពាររបស់មេធាវីជនជាប់ចោទ

- ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ

## តុលាការកំពូល

- យល់ឃើញថាបណ្តឹងសាទុក្ខលេខ ០៦ ចុះថ្ងៃទី២៧ ខែមករា ឆ្នាំ១៩៩៨ របស់ជនជាប់ចោទឈ្មោះ វ៉ន្ត គីមឡេង ធ្វើឡើងក្នុងកំណត់ច្បាប់តុលាការកំពូលអាចលើករឿងនេះមកជំនុំជំរះបានតាមមាត្រា១៤ នៃច្បាប់ស្តីពីការចាត់តាំងតុលាការ និង សកម្មភាពរបស់សាលាជំរះក្តី ។

- យល់ឃើញថាការដែលតុលាការក្រុងភ្នំពេញ និង សាលាឧទ្ធរណ៍សំរេចដាក់បន្ទុកតែទៅលើជនជាប់ចោទដោយពុំបានពិចារណាអំពីកំហុសឆ្គងរបស់ជនរងគ្រោះផងនោះ គឺជាការពុំត្រឹមត្រូវទេឡើយ ពីព្រោះថាចម្លើយរបស់ជនរងគ្រោះនៅចំពោះមុខតុលាការថ្នាក់ក្រោមបានបញ្ជាក់អោយឃើញថា :

- ជនរងគ្រោះ ដែលជាអ្នកបើកបរម៉ូតូឆាលីជាអនីតិជន
- ជនរងគ្រោះ ដែលជាអ្នកបើកបរម៉ូតូហុងដា សេ១០០ពុំមានប័ណ្ណបើកបរទេឡើយ
- ទាំងម៉ូតូឆាលី ទាំងម៉ូតូហុងដា សេ១០០ សុទ្ធតែឌុបគ្នា លើសពីមួយនាក់

ដែលជាការរំលោភទៅនឹងមាត្រា១០ និង មាត្រា៣០ នៃច្បាប់ចរាចរណ៍ផ្លូវគោក ទៅនឹងបទកំណត់ចំនួនមធ្យោបាយចរាចរ និង ឈ្នាប់ខ្នាប់ ចុះថ្ងៃទី០៧-១០-៨៧ និង សេចក្តីជូនដំណឹងចំពោះអ្នកប្រើប្រាស់ទោចក្រយានយន្តគ្រប់ប្រភេទ ក្នុងរាជធានីលេខ១៣៦សជណ ចុះថ្ងៃទី១៤-១២-៩៤ របស់សាលាក្រុងភ្នំពេញ ដូច្នេះជនរងគ្រោះក៏ត្រូវរួមចំណែកក្នុងការទទួលខុសត្រូវអំពីព្យសនកម្មដែលបណ្តាលមកពីគ្រោះថ្នាក់ចរាចរនេះដែរ តាមមាត្រា១៣៤ នៃក្រិត្យច្បាប់លេខ ៣៨ក្រច ។

យល់ឃើញថា កំណត់បង្ហាញស្តីពីសេចក្តីសន្និដ្ឋានរឿងគ្រោះថ្នាក់ចរាចរចុះថ្ងៃទី២៧-០២-៩៦ របស់មន្ត្រីនគរបាលចរាចរ និង របាយការណ៍ លេខ ០៦០រប ចុះថ្ងៃទី០២-៣-៩៦ របស់អធិការដ្ឋាននគរបាលខ័ណ្ឌមានជ័យ បញ្ជាក់អោយឃើញថា ការដែលជនជាប់ចោទ បើកបររថយន្តហុងដាអាកូរ៉ា ជ្រុលទៅបុកជនរងគ្រោះនោះ គឺបណ្តាលមកពីជនជាប់ចោទខ្វះការត្រួតពិនិត្យកង់រថយន្ត របស់ខ្លួនបណ្តាលអោយដុះកង់មុខទាញចង្កូតជ្រុលទៅបុកជនរងគ្រោះ ។

- យល់ឃើញថា សាលដីកាព្រហ្មទណ្ឌលេខ២៤៣ ចុះថ្ងៃទី១៩ ខែធ្នូ ឆ្នាំ១៩៩៧ របស់សាលាឧទ្ធរណ៍ ដែលបានសំរេចសេចក្តីមកនេះ មានការខុសឆ្គងទាំងទំរង់ ទាំងអង្គច្បាប់ ។

## ហេតុដូច្នេះ

វិនិច្ឆ័យសេចក្តីចំពោះមុខជនជាប់ចោទ និង ដើមបណ្តឹងរដ្ឋប្បវេណី

១ - ទទួលបណ្តឹងសាទុក្ខលេខ ០៦ ចុះថ្ងៃទី២៧ ខែមករា ឆ្នាំ១៩៩៨ របស់ជនជាប់ចោទ

ឈ្មោះ វ័ន្ត គីមទៀង ទុកជាត្រឹមត្រូវតាមទំរង់ និង គតិច្បាប់ ។

២ - ទុកជាមោឃៈសាលដីកាព្រហ្មទណ្ឌលេខ២៤៣ ចុះថ្ងៃទី១៩ ខែធ្នូ ឆ្នាំ១៩៩៧ របស់សាលាឧទ្ធរណ៍ទាំងមូល ។

៣ - បង្វិលសំណុំរឿងព្រហ្មទណ្ឌលេខ ១៦ ចុះថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ១៩៩៨ របស់តុលាការកំពូល ទៅសាលាឧទ្ធរណ៍ដើម្បីជំនុំជំរះជាថ្មីឡើងវិញ ។

៤ - សាលដីកានេះប្រកាសជាសាធារណៈនៅថ្ងៃទី២៣ ខែកញ្ញា - ឆ្នាំ ១៩៩៨ ។